Embassy of Japan
in the Kingdom of Cambodia

# Press Release

No. 30 PR-19 / EoJ

31 May, 2019

## 2019 Spring Conferment of Decoration the Order of the Sacred Treasure, Gold Rays with Neck Ribbon is conferred to Dr. Takeshi Nakagawa, Professor Emeritus of Waseda University, Japan

On 30 May, 2019, **Dr. Takeshi Nakagawa**, Professor Emeritus of Waseda University, Japan, attended the presentation ceremony to receive **the Order of the Sacred Treasure, Gold Rays with Neck Ribbon** and was given an audience by His Majesty the Emperor at the Imperial Palace in Japan, following the announcement of the 2019 Spring Conferment of Decorations, which are bestowed upon individuals of merit in recognition of their national or public services, and in honour of their distinguished accomplishments in various areas in society, by the Cabinet Office of the Government of Japan on 21 May, 2019.

**Dr. Takeshi Nakagawa**, has contributed to promotion of academic exchange between Japan and Cambodia through conservation and restoration of the Angkor especially Bayon Temple as the Director of Japanese Government team for Safeguarding Angkor (JSA) since its establishment in 1994 and as the Co-Director of JAPAN-APSARA Safeguarding Angkor (JASA) from 2005 and fostering a number of Cambodian technical experts for the Angkor projects for more than 25 years.

**Dr. Takeshi Nakagawa** has also been contributing to the conservation, restoration, and research activities in Preah Vihear Temple and Sambor Prei Kuk, the other UNESCO World Heritage sites of Cambodia, as the head of Waseda University's team.

**ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា**

# សេចក្តីប្រកាសព័ត៌មាន

លេខៈ 30 PR-19/EoJ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៩

## ការប្រគល់គ្រឿងឥស្សរិយយសសម្រាប់និទាឃរដូវឆ្នាំ២០១៩
The Order of the Sacred Treasure, Gold Rays with Neck Ribbon
## ជូនលោកបណ្ឌិត តាកេស៊ី ណាកាហ្គាវ៉ា សាស្ត្រាចារ្យកិត្តិយស នៃសាកលវិទ្យាល័យវ៉ាសេដា ប្រទេសជប៉ុន

ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩ លោកបណ្ឌិត **តាកេស៊ី ណាកាហ្គាវ៉ា** សាស្ត្រាចារ្យកិត្តិយសនៃសាកលវិទ្យាល័យវ៉ាសេដា ប្រទេសជប៉ុន បានចូលរួមពិធីប្រគល់គ្រឿងឥស្សរិយយសដើម្បីទទួលគ្រឿងឥស្សរិយយស "The Order of the Sacred Treasure, Gold Rays with Neck Ribbon" នឹងចូលបង្គំគាល់ព្រះករុណា ព្រះចៅអធិរាជ នៅព្រះបរមរាជវាំងប្រទេសជប៉ុន បន្ទាប់ពីរដ្ឋាភិបាលជប៉ុន បានប្រកាសឈ្មោះអ្នកទទួលគ្រឿងឥស្សរិយយសសម្រាប់និទាឃរដូវឆ្នាំ២០១៩ កាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៩ ដល់បុគ្គលដែលមានស្នាដៃឆ្នើមសម្រាប់សង្គម ផលប្រយោជន៍សាធារណៈ ឬ ប្រទេសជាតិ។

លោកបណ្ឌិត **តាកេស៊ី ណាកាហ្គាវ៉ា** បានរួមចំណែកជម្រុញការអប់រំ និងមិត្តភាពរវាងប្រទេសជប៉ុន និងប្រទេសកម្ពុជា តាមរយៈការជួសជុល និងស្តារឡើងវិញនៃអង្គរ ជាពិសេសប្រាសាទបាយ័ន ក្នុងនាមលោកជាប្រធានក្រុមរដ្ឋាភិបាលជប៉ុនសម្រាប់ការថែរក្សាការពារប្រាសាទអង្គរ(JSA) ចាប់តាំងពីបង្កើតឡើងនៅឆ្នាំ១៩៩៤ និងក្នុងនាមជាសហប្រធាននៃគម្រោងជប៉ុន-អប្សរាការពារប្រាសាទអង្គរ (JASA) ចាប់ពីឆ្នាំ២០០៥ ព្រមទាំងបណ្តុះបណ្តាលអ្នកជំនាញបច្ចេកទេសកម្ពុជាជាច្រើនរូប សម្រាប់គម្រោងអង្គរជាង២៥ឆ្នាំមកនេះ។

លោកបណ្ឌិត **តាកេស៊ី ណាកាហ្គាវ៉ា** បានរួមចំណែកការជួសជុល ការស្តារឡើងវិញ និងសកម្មភាពស្រាវជ្រាវនៅប្រាសាទព្រះវិហារ និងសំបូរព្រៃគុក ដែលជាបេតិកភណ្ឌពិភពលោកនៃអង្គការយូណេស្កូ របស់កម្ពុជា ក្នុងនាមលោកជាប្រធានក្រុម នៃសាកលវិទ្យាល័យវ៉ាសេដា។